# ស្ថានទូតជប៉ុន
# ប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសពត៌មាន

លេខ. 13-PR-17/EoJ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧

## ជប៉ុនផ្តល់ ២៧៩,០៣៨ ដុល្លារអាមេរិក សម្រាប់លើកកម្ពស់ការអប់រំបញ្ចូលគ្នានៅកម្ពុជា

ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន ផ្តល់ថវិកាចំនួន ២៧៩,០៣៨ ដុល្លារអាមេរិក ដល់អង្គការសមាគមន៍សម្រាប់ជំនួយនិងសង្គ្រោះនៃប្រទេសជប៉ុន (អង្គការAARជប៉ុន)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកស្រី សូណូដា តូម៉ូកូ នាយិកាការិយាល័យភ្នំពេញនៃអង្គការAARជប៉ុន ដើម្បីអនុវត្ត "គម្រោងលើកកម្ពស់ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការក្នុងខេត្តកណ្តាល (ដំណាក់កាលទី៣)" នៅស្ថានទូតជប៉ុន។

អង្គការAARជប៉ុន នឹងជួយលើកកម្ពស់ការអប់រំបញ្ចូលគ្នា តាមរយៈការបង្កើតអោយមានជម្រាលសម្រាប់កុមារពិការនៅក្នុងសាលារៀន និងការរៀបចំអោយមានការបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់កុមារពិការ នៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ជាមួយនឹងគម្រោងនេះ ប្រជាជនប្រមាណជា ២, ៣០០នាក់នៅក្នុងសហគមន៍ នឹងទទួលបានចំណេះដឹងអំពីពិការភាព ហើយគម្រោងនេះ រំពឹងថា នឹងនាំអោយអត្រានៃការចូលរៀនរបស់កុមារពិការមានចំនួនកើនឡើង។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង ២៨.៧លានដុល្លារអាមេរិក ដល់គម្រោងចំនួន ១០០គម្រោង ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះ គឺជាគម្រោងទី១ ដែលបានផ្តល់ជូនដោយគ្រោងការណ៍នៃជំនួយនេះនៅកម្ពុជាសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៧របស់ជប៉ុន (មេសា២០១៧ ដល់មីនា២០១៨)។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៦-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*